*ភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥*

*ឯកឧត្តម ដុន បេនតុន*
*សមាជិកព្រឹទ្ធសភា*
*ព្រឹទ្ធសភារដ្ឋវ៉ាស៊ីងតោន*
*វេនគូវើ វ៉ាស៊ីងតោន*

*សមាជិកព្រឹទ្ធសភា បេនតុន*

*ខ្ញុំសូមសម្តែងនូវអំណរគុណដ៏ស្មោះស្ម័គ្រចំពោះសមានចិត្ត និងការគាំទ្រដ៏ខ្លាំងក្លារបស់* ***ឯកឧត្តម*** *ដែលបានផ្តល់ជូនខ្ញុំក្នុងលិខិតរបស់***ឯកឧត្តម** *ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ សំរាប់អ្វីដែលខ្ញុំបានធ្វើដើម្បីការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា។*

*ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែល***ឯកឧត្តម***បានយល់ដឹងច្បាស់អំពីអ្វីដែលបានកើតឡើងនៅប្រទេសកម្ពុជាពាក់ព័ន្ធនឹងបញ្ហាផែនទី និងព្រំដែន។ ការយល់ឃើញរបស់***ឯកឧត្តម***ថាការវាយប្រហារមកលើខ្ញុំ និងរាជរដ្ឋាភិបាលរបស់ខ្ញុំលើបញ្ហាទាំងនេះ គឺវា«***គ្មានមូលដ្ឋាន***» និង «***មានហេតុ ផលនយោបាយ***» ជាការផ្តល់យុត្តិធម៌ដល់កិច្ចខិតខំប្រឹងប្រែងរបស់ខ្ញុំ និងរាជរដ្ឋាភិបាលរបស់ខ្ញុំ។*

*ខ្ញុំក៏យល់ឃើញដូច***ឯកឧត្តម***ទាំងស្រុងដែរថា តួនាទីមួយក្នុងចំណោមតួនាទីដ៏សំខាន់បំផុតរបស់ថ្នាក់ដឹកនាំប្រទេស និងរបស់រដ្ឋាភិបាល គឺការការពារ និងថែរក្សាអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេស។*

*ក្នុងការកំណត់ព្រំដែន និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងប្រើប្រាស់ ហើយនឹងបន្តប្រើប្រាស់ផែនទីបោនខ្នាត១/១០០.០០០ បោះពុម្ពដោយសេវាកម្មភូមិសាស្ត្រឥណ្ឌូចិន ស្របតាមមាត្រា២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។*

*ក្រៅពីនេះ ការអនុម័តដោយរដ្ឋសភាជាតិ និងការផ្តល់សច្ចាប័នដោយព្រះមហាក្សត្រទៅលើសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ បានបង្ហាញពីភាពត្រឹមត្រូវនៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា នៅក្នុងទសវត្សរ៍ទី៨០ ស្តីពីការកំណត់ព្រំដែន និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។*

កំប៉ុន្តែគណបក្សប្រឆាំងបានប្រើប្រាស់បញ្ហាព្រំដែនក្នុងយុទ្ធនាការប្រឆាំងរាជរដ្ឋាភិបាល ក្នុងគោលបំណងកេងចំណេញនយោបាយ។ គេបានឈានទៅដល់ការចោទប្រកាន់ថា រាជរដ្ឋាភិបាលបានប្រើប្រាស់ **«ផែនទីក្លែងក្លាយ»** ហើយជាងនេះទៅទៀត **«ផែនទីចោរ»**។ ទង្វើដែលគ្មានការគិតគូពីផលវិបាកទាំងនេះរបស់គណបក្សប្រឆាំងគឺមានគោលដៅបំភ័ន្តសាធារណៈមតិជាតិ និងអន្តរជាតិ។

ប្រឈមមុខនឹងយុទ្ធនាការបោកបំភ័ន្តដ៏ធំនេះ និងដើម្បីផ្តល់ការបំភ្លឺជូនប្រជាពលរដ្ឋខ្មែរទាំងអស់អំពីផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ក្នុងការកំណត់ព្រំដែន និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម ខ្ញុំបានសរសេរលិខិតទៅ អគ្គលេខាធិការអង្គការសហប្រជាជាតិ **ឯកឧត្តម បាន គីមូន** ប្រធានាធិបតីបារាំង **ឯកឧត្តម ហ្វ្រង់ស័រ ហូឡង់** នាយករដ្ឋមន្ត្រីចក្រភពអង់គ្លេស **ឯកឧត្តម ដាវីត កាមេរ៉ុន** និងប្រធានាធិបតីសហរដ្ឋអាមេរិច **ឯកឧត្តម បារ៉ាក់ អូបាម៉ា** ដើម្បីសុំខ្ចីផែនទីដើម ឬផែនទីចម្លងដែលគេមាន យកមកផ្ទៀងផ្ទាត់ជាមួយផែនទីផ្លូវការនិងស្របច្បាប់ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រើ និងកំពុងប្រើប្រាស់។

ឆ្លើយតបនឹងសំណើរបស់ខ្ញុំ អគ្គលេខាធិការអង្គការសហប្រជាជាតិ **ឯកឧត្តម បាន គីមូន** បានឲ្យខ្ចីផែនទីចំនួន១៨ផ្ទាំង ហើយប្រធានាធិបតីបារាំង **ឯកឧត្តម ហ្វ្រង់ស័រ ហូឡង់**បានផ្តល់ជូននូវផែនទីចម្លងពេញខ្នាត១/១០០.០០០ ចំនួន២៦ផ្ទាំង។ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិច មិនអាចរកឃើញផែនទីដែលកម្ពុជាបានស្នើសុំនោះទេ។

ដំណើរការផ្ទៀងផ្ទាត់ទាំងពីរលើក នៃផែនទីរបស់អង្គការសហប្រជាជាតិ និងផែនទីបារាំង ដែលត្រូវបានធ្វើឡើងក្រោមការចូលរួមជាសាក្សីរបស់តំណាងពីគណបក្សប្រជាជនកម្ពុជា ( គណបក្សរបស់ខ្ញុំ ) គណបក្សប្រឆាំង គណបក្សហ្វ៊ុនស៊ិនប៉ិច រដ្ឋសភា ព្រឹទ្ធសភា ។ល។ បានបញ្ជាក់យ៉ាងច្បាស់ថា ផែនទីទាំងនេះដូចគ្នាបេះបិទនឹងផែនទីរបស់រាជរដ្ឋាភិបាល។

បន្ទាប់ពីការផ្ទៀងផ្ទាត់ផែនទីទាំងពីរលើកនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថាបញ្ហាផែនទី និងព្រំដែនត្រូវបានបញ្ចប់ហើយ។

ខ្ញុំជឿជាក់យ៉ាងមុះមុតថា អ្វីដែលខ្ញុំ និងរាជរដ្ឋាភិបាលរបស់ខ្ញុំបានធ្វើក្នុងការកំណត់ព្រំដែន និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម បានបង្ហាញយ៉ាងច្បាស់នូវការខិតខំយ៉ាងធំធេងក្នុងការការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា។

ជាថ្មីម្តងទៀត ខ្ញុំសូមអរគុណចំពោះការគាំទ្ររបស់**ឯកឧត្តម**។

សូម**ឯកឧត្តម**ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**